**សិទ្ធិស្ត្រី ជាសិទ្ធិមនុស្ស៖ កម្ពុជាត្រូវគោរពសិទ្ធិស្វ័យសម្រេច**
**សិទ្ធិសម្តែងមតិ អារម្មណ៍ និងជម្រើសរាងកាយរបស់ស្ត្រី**

**លិខិតចំហគោរពជូនចំពោះ**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ភ្នំពេញ ថ្ងៃ១១រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០

យើងខ្ញុំជាតំណាងអង្គការសង្គមស៊ីវិល ដែលធ្វើការដើម្បីលើកកម្ពស់សិទ្ធិស្ត្រីនិងសមភាពយេនឌ័រនៅកម្ពុជា សូមទទួលស្គាល់នូវផ្ទៃនូវៈដ៏ខ្ពង់ខ្ពស់និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចការលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅក្នុងវិស័យនានា និង គ្រប់កម្រិត ជាពិសេសការខិតខំប្រឹងប្រែងក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រីនិងក្មេងស្រី លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្ត ការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច។ល។ សមិទ្ធិផលគួរឱ្យកោតសរសើរទាំងនេះ រាជរដ្ឋាភិបាល បាននឹងកំពុងបំពេញកាតព្វកិច្ចក្នុងនាមជារដ្ឋភាគីនៃអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(ស៊ី.ដ) និងតាមរយៈការអនុវត្តច្បាប់និងគោលនយោបាយជាតិនានា ជាពិសេស យុទ្ធសាស្ត្រចតុកោណ ផែនការអភិវឌ្ឍន៍ប្រកបដោយចីរភាព ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ គោលនយោបាយសមភាពយេនឌ័រ ផែនការយុទ្ធសាស្ត្រលើកកម្ពស់សមភាពយេនឌ័រនិងបង្កើនភាពអង់អាចដល់ស្ត្រី(នារីរតនៈ) និងផែនការបញ្ជ្រាបយេនឌ័រតាមវិស័យនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

នាថ្ងៃទី៩រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែកុម្ភៈឆ្នាំ២០២០ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីបានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ ក្នុងឱកាសនៃកិច្ចប្រជុំនេះ សម្តេច បានមានមតិសំណេះសំណាលដោយភ្ជាប់ទៅនឹងការរិះគន់ទៅដល់ស្ត្រីដែលប្រកបរបររកស៊ីតាមអនឡាញ ហើយនិងការស្លៀកពាក់របស់ពួកគេ និងបានផ្តល់អនុសាសន៍ជំរុញដល់គណៈកម្មការជាតិដើម្បីលើកកម្ពស់តម្លៃស្ត្រីនិងគ្រួសារខ្មែរ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងមហាផ្ទៃនិងអាជ្ញាធរ បង្កើនការស៊ើបអង្កេតនិងបង្ក្រាបតាមប្រព័ន្ធបច្ចេកវិទ្យាដែលធ្វើឱ្យប៉ះពាល់ដល់សីលធម៌សង្គម តម្លៃស្ត្រីខ្មែរ និងវប្បធម៌ជាតិ។ វិធានការនេះជាការព្រួយបារម្ភសម្រាប់យើងខ្ញុំទាំងអស់គ្នាដែលធ្វើកិច្ចការដើម្បីលើកកម្ពស់សិទ្ធិស្ត្រីនិងសមភាពយេនឌ័រនៅកម្ពុជា។ អនុសាសន៍របស់សម្តេចក្នុងផ្នែកនេះហាក់ដូចជា មិនស្របទិសគ្នាជាមួយនឹងអនុសញ្ញាស៊ី.ដ ព្រមទាំងច្បាប់និងគោលនយោបាយជាតិនានា ដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងអនុវត្តនិងយកចិត្តទុកដាក់ ដូចដែលបានរៀបរាប់ខាងលើ។

ការលើកឡើងរបស់សម្តេចអំពីការរិះគន់លើរាងកាយស្ត្រី ការរឹតបន្តឹងទៅលើសិទ្ធិសេរីភាពនៃការស្លៀកពាក់របស់ស្ត្រីដែលយល់ថាប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរនិងវប្បធម៌ប្រពៃណីជាតិ កន្លងមកមិនមានឯកសារផ្លូវច្បាប់ ឬឯកសារផ្លូវការណាមួយដែលផ្តល់និយមន័យអំពី“តម្លៃស្ត្រី និងតម្លៃសង្គម ឬ វប្បធម៌ខ្មែរ” ឬពន្យល់អំពីគោលបំណងនៃការលើកកម្ពស់បញ្ញត្តិទាំងនេះនោះទេ។ គួរកត់សម្គាល់ដែលថាតម្លៃសង្គមមានលក្ខណៈលម្អៀងមានការយល់ឃើញខុសៗគ្នា អាស្រ័យទៅតាមបរិបទផ្សេងគ្នានិងមានការប្រែប្រួលឥតឈប់ឈរ។ មិនតែប៉ុណ្ណោះក៏ពុំទាន់មានការសិក្សាបែបស៊ីជម្រៅណាមួយ ដែលបញ្ជាក់ថាការស្លៀកពាក់របស់ស្ត្រីជាដើមហេតុនៃការការបង្កឱ្យមានឱនភាពនៃសីលធម៌សង្គមនោះដែរ។ ផ្ទុយទៅវិញនៅកម្ពុជាកម្រមានការពិភាក្សានិងសិក្សាអំពីសីលធម៌សង្គមដែលដាក់បន្ទុកលើបុរសកុំឱ្យប្រព្រឹត្តអំពើហិង្សាលើស្ត្រី និងក្មេងស្រីណាស់ ដែលធ្វើឱ្យជនប្រព្រឹត្តដែលមិនត្រូវបានដាក់ទោសទណ្ឌ ត្រូវបានពង្រឹងភាពអង់អាចកាន់តែខ្លាំងក្លាឡើងក្នុងការប្រព្រឹត្តិអំពើហិង្សាបន្តទៀត។

ប្រសាសន៍របស់សម្តេចដែលយល់ថាការដែលស្ត្រីស្លៀកពាក់លេចលើលេចក្រោមនាំឱ្យមានការរំលោភបំពាន គឺជាការស្តីបន្ទោសជនរងគ្រោះ ហើយការពង្រឹងវប្បធម៌ស្តីបន្ទោសជនរងគ្រោះនេះ នឹងធ្វើឲ្យអំពើហិង្សាលើស្ត្រីនិងការរើសអើងផ្អែកលើយេនឌ័រនៅតែបន្តកើតឡើងនៅក្នុងសង្គមកម្ពុជា។ ចំណាត់ការដែលដាក់ចេញដោយសម្តេចហាក់ផ្ទុយទៅនឹងឯកសារបទដ្ឋានអប្បបរមាសម្រាប់ការផ្តល់ប្រឹក្សាជាមូលដ្ឋានដល់ស្ត្រីនិងក្មេងស្រីជាជនរងគ្រោះដោយសារអំពើហិង្សាផ្អែកលើយេនឌ័រ ដែលត្រូវបានរៀបចំបង្កើតឡើងដោយក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលក្នុងឆ្នាំ២០១៦បានចែងថា អ្នកផ្តល់សេវា “មិនត្រូវស្តីបន្ទោសជនរងគ្រោះ” និង “មិនត្រូវសួរជនរងគ្រោះថាតើពួកគេបានធ្វើអ្វីខ្លះដែលនាំអោយមាន អំពើហិង្សាកើតឡើងនោះទេ”។ ក្នុងខែមករាឆ្នាំ ២០២០ មន្ត្រីតំណាងមកពី ក្រសួងកិច្ចការនារី ក្រសួងព័ត៌មាន និងក្រសួងវប្បធម៌ និង

វិចិត្រសិល្បៈ សុទ្ធតែបានលើកឡើងជាសាធារណៈអំពីជំហរដូចគ្នាដែរថា "ការស្លៀកពាក់ខើចលើខើចក្រោមហួសហេតុ រួមទាំងការប្រើភាសាអាសគ្រាមនៅពេលលក់ផលិតផលតាមអនឡាញ" នោះគឺជាសិទ្ធិបុគ្គល[1]។

ការអះអាងថា"ស្ត្រីដែលស្លៀកពាក់ខ្លីលេចលើលេចក្រោមជាការជំរុញឲ្យបុរសប្រព្រឹត្តអំពើហិង្សាផ្លូវភេទ និង មានការជួញដូរមនុស្ស" គឺទស្សនៈខុសឆ្គងភាន់ច្រឡំនិងមិនគួរត្រូវបានលើកទឹកចិត្តនោះទេ។ ផ្ទុយទៅវិញតាមការស្រាវជ្រាវជាច្រើនបានបង្ហាញថាអំពើហិង្សាលើស្ត្រីផ្តើមចេញពីផ្នត់គំនិតរើសអើងយេនឌ័រ វប្បធម៌ស្ដីបន្ទោសជនរង គ្រោះដែលចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងសង្គមកម្ពុជា ការអនុវត្តច្បាប់មិនទាន់បានរឹងមាំ និងវប្បធម៌និទណ្ឌភាព មិនមែនផ្អែកទៅលើការស្លៀកពាក់ ឬរូបរាងកាយ ឬទង្វើរបស់ស្ត្រីនោះទេ។

រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាសម្រេចឲ្យបាននូវ "យុគសម័យសមភាពយេនឌ័រ" "យុគសម័យបដិវត្តឧស្សាហកម្មជំនាន់ទី៤" និង "ការមិនទុកអ្នកណាម្នាក់ឲ្យនៅឯកា" ដើម្បីឈានទៅសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ស្ត្រីដែលកំពុងតែប្រកបអាជីវកម្មអនឡាញ កំពុងទទួលបាននូវការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច តាមរយៈការទាញយកប្រយោជន៍ពីការប្រើប្រាស់មធ្យោបាយបច្ចេកវិទ្យានានា ដែលពួកគេអាចប្រើប្រាស់បាន និងមានភាពងាយស្រួលដោយភាពច្នៃប្រឌិតទៅតាមតម្រូវការរបស់អតិថិជនរបស់ពួកគេ។ ហេតុដូច្នេះ រាជរដ្ឋាភិបាលគួរបន្តគាំទ្រសហគ្រិនភាពរបស់ស្ត្រី និងគាំទ្រសិទ្ធិរបស់ស្ត្រីចំពោះជម្រើសក្នុងការប្រើប្រាស់រាងកាយរបស់ពួកគេផងដែរ។

យើងខ្ញុំ សូមជំរុញដល់រាជរដ្ឋាភិបាលកម្ពុជា ខិតខំប្រឹងប្រែងអនុវត្តបន្ថែម ចំពោះកាតព្វកិច្ចតាមអនុសញ្ញាស៊ីដ មាត្រា៥ ដែលតម្រូវឲ្យរដ្ឋភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ដើម្បីកែប្រែឥរិយាបថសង្គម និងវប្បធម៌របស់បុរសនិងស្ត្រី ដើម្បីសម្រេចបាននូវការលុបបំបាត់ចោលសេចក្តីលំអៀង និងទម្លាប់ និងការអនុវត្តជាទម្លាប់ផ្សេងៗទៀតផ្អែកលើគំនិតស្ដីពីភាពទាបជាងឬខ្ពស់ជាងរបស់ភេទណាមួយ ឬលើតួនាទីជាទម្លាប់សម្រាប់បុរសនិងស្ត្រី។ ព្រមទាំងអនុវត្តនូវសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ ស៊ី ដ ឆ្នាំ២០១៩ កថាខណ្ឌ ២៥(ក) ដែលតម្រូវឲ្យ រដ្ឋាភិបាល "វាយតម្លៃប៉ាន់ប្រមាណជាលក្ខណៈប្រព័ន្ធទៅលើផលប៉ះពាល់នៃវិធានការនានាដែលបានអនុម័តឡើងនៅក្នុងការ ប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាផ្អែកលើយេនឌ័រទៅស្ត្រីនិងក្មេងស្រី និងបន្តស្វែងរកវិធីសាស្រ្តថ្មីៗដើម្បីដោះស្រាយនូវបុព្វហេតុ ឫសគល់នៃអំពើហិង្សា។

ដូច្នេះការដាក់ទណ្ឌកម្មទៅលើស្ត្រីដោយសារតែជម្រើសនៃការស្លៀកពាក់របស់ពួកគេ គឺជាឫសគល់នៃអំពើហិង្សានិងការរើសអើងលើស្ត្រី វាមិនមែនជាដំណោះស្រាយនោះទេ ដែលរាជរដ្ឋាភិបាលគួរធ្វើការពិចារណាឡើងវិញ។ យើងខ្ញុំ សូមអំពាវនាវ ដល់រាជរដ្ឋាភិបាលក្នុងការធានាថា **កម្ពុជានឹងគោរពសិទ្ធិស្វ័យសម្រេច សិទ្ធិសម្តែងមតិ អារម្មណ៍ និងជម្រើសរាងកាយរបស់ស្ត្រី** ដើម្បីសម្រេចបានការលើកកម្ពស់សមភាពយេនឌ័រ និងបញ្ឈប់អំពើហិង្សាផ្អែកលើយេនឌ័រនៅកម្ពុជា៕

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
អ្នកស្រី ជឹម ចាន់នាង, អគ្គលេខាធិការអង្គការ អិនជីអូ ស៊ី ដ, 012 668 853
អ្នកស្រី អ៊ុំ សុភារី, អ្នកសម្របសម្រួលយុទ្ធនាការ នៃអង្គការអោក់សិនអេតកម្ពុជា, 012 621 822
អ្នកស្រី បុណ្យ រចនា, នាយិកាប្រតិបត្តិអង្គការក្លាហាន, 089 476 146
លោក សុខ លាំង, អ្នកជំនាញឯករាជ្យផ្នែកយេនឌ័រ និងសង្គមវិទ្យា, 012 588 081
អ្នកស្រី អេង ច័ន្ទឌី, អ្នកគ្រប់គ្រងកម្មវិធីតស៊ូមតិនិងបណ្តាញ នៃអង្គការយេនឌ័រនិងការអភិវឌ្ឍន៍ដើម្បីកម្ពុជា, 095 797 909
អ្នកស្រី ឌួង ចាន់សេរីសាល, នាយិកាប្រតិបត្តិ នៃអង្គការបន្ទាយស្រេ, 012 489 358
អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិមជ្ឈមណ្ឌលសិទ្ធមនុស្សកម្ពុជា 011 943 213

[1] http://angkorbest.xyz/article/3273